# ចំណងស្នេហ៍



សៀវភៅណែនាំគូស្នេហ៍អំពីទំនាក់ទំនងស្នេហា

USAID
ជំនួយពីពលរដ្ឋអាមេរិក

psi
Cambodia

# មាតិកា


- ភាពផ្អែមល្ហែម ..... 4
- ការរួមភេទ ..... 6
- សរីរាង្គបុរស-ស្ត្រី ..... 7
- ការពន្យារកំណើត ..... 8
- មធ្យោបាយពន្យារកំណើតបែបទំនើប ..... 9
- ចំណុចគួរពិចារណា ..... 12
- សំណួរចម្លើយ ..... 14

# ភាពផ្អែមល្ហែម



ទោះបីជាអ្នករស់នៅជាមួយគ្នាយូរប៉ុណ្ណាក៏ដោយ ប៉ុន្តែប្រការសំខាន់
គឺផ្តល់ក្តីស្រលាញ់ឱ្យគូស្នេហ៍របស់អ្នក។

# គន្លឹះពិសេសៗសម្រាប់ចំណងស្នេហ៍ឱ្យកាន់តែមានភាពផ្អែមល្ហែម




ផ្ញើសារ "អូនស្រលាញ់បង ឬបងស្រលាញ់អូន"



ផ្អែមល្ហែមរៀងរាល់ថ្ងៃ



ជូនវត្ថុអនុស្សាវរីយ៍



ជួយការងារផ្ទះ




និយាយអរគុណលើកទឹកចិត្ត



ផ្ដល់ក្ដីស្រលាញ់ដោយកាយវិការ



ចំណាយពេលដ៏មានតំលៃជាមួយគ្នា



កាន់ដៃគ្នា
នៅទីសាធារណៈ

**ឥឡូវវេនអ្នកម្ដង៖ ចំណាយពេលសាសងជាមួយគ្នា នូវអ្វីដែលអ្នកទាំងពីរអាចផ្ដល់សេចក្ដីស្រឡាញ់ឱ្យគ្នាទៅវិញទៅមក**

**សម្រង់សំដីស្នេហ៍៖** ស្នេហ៍មួយគ្មានពីរ ស្នេហ៍តែឆវី ពិសីល្អឯក បងសូមសារភាព ចិត្តមិនរារែក ស្នេហ៍មួយមិនបែក ស្នេហ៍អូនលុះក្ស័យ។

# ការរួមភេទ



ការរួមភេទជាសកម្មភាពមួយ ដែលគូស្នេហ៍អាចសប្បាយជាមួយគ្នា។ ប៉ុន្តែភាគច្រើនអ្នកទាំងពីរគ្មានពេលនៅជាមួយគ្នា ឬមិនដឹងថា "តើធ្វើយ៉ាងណា ដើម្បីឱ្យដៃគូម្ខាងទៀតមានអារម្មណ៍រំភើបសុខស្រួល" ជជែកអំពីរឿងនេះ!

# សរីរាង្គបុរស-ស្ត្រី



ការរួមភេទមិនមែនសម្រាប់ត្រឹមតែបន្តពូជប៉ុណ្ណោះទេ។
សាកសួរគូស្នេហ៍របស់អ្នក៖

- តើយើងអាចរកពេលនៅសប្បាយជាមួយគ្នាតាមរបៀបណា ?
- តើអ្នកចង់ឱ្យបបោសអង្អែលត្រង់ណា ?
- តើអ្នកសម្រេចដល់កម្រិតកំពូលតាមវិធីណា ?
- តើយើងត្រូវធ្វើយ៉ាងណា ដើម្បីយើងអាចធ្វើការរួមភេទ ពេលណាដែលយើងចង់ ដោយមិនមានការបារម្ភពីការមានកូន ?

# ការពន្យារកំណើត



ប្រសិនបើអ្នកមិនទាន់ចង់មានកូនទេ វាគឺសំខាន់ណាស់ដែលអ្នកត្រូវដឹងពីជម្រើសនៃមធ្យោបាយពន្យារកំណើតបែបទំនើបមួយណាដែលសមស្របសម្រាប់អ្នក ដើម្បីការពារកុំឱ្យមានផ្ទៃពោះដែលមិនចង់បាន។

# មធ្យោបាយពន្យារកំណើតបែបទំនើប



កងដាក់ក្នុងស្បូន



កងដាក់ក្រោមស្បែក



ថ្នាំចាក់ពន្យារកំណើត



ថ្នាំគ្រាប់ពន្យារកំណើត



ស្រោមអនាម័យ




ថ្នាំគ្រាប់ការពារកំណើតបន្ទាន់



មធ្យោបាយបញ្ឈប់កំណើត

# ការប្រើមធ្យោបាយពន្យារកំណើតបែបទំនើបមានន័យថា ជាការសន្សំប្រាក់ និងផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់គ្រួសារ

| មធ្យោបាយពន្យារកំណើតបែបទំនើប | ប្រសិទ្ធភាពប្រើប្រាស់ | ការពារការមានផ្ទៃពោះ | មានផ្ទៃពោះវិញបន្ទាប់ពីឈប់ប្រើ | ភាពងាយស្រួល |
|---|---|---|---|---|
| កងដាក់ក្នុងស្បូន | ១០ឆ្នាំ | 😀 | 😀 | 🙂 |
| កងដាក់ក្រោមស្បែក | ៣-៥ឆ្នាំ | 😀 | 😀 | 🙂 |
| ថ្នាំចាក់ពន្យារកំណើត | ៣ខែ | 😀 | 🙂 | 🙂 |
| ថ្នាំគ្រាប់ពន្យារកំណើត | លេបរាល់ថ្ងៃ | 🙂 | 😀 | 🙂 |
| ស្រោមអនាម័យ | រាល់ពេលរួមភេទ | 🙂 | 😀 | ☹️ |
| ៧២ ម៉ោង ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ | អំឡុងពេល ៧២ម៉ោង | 🙂 | 😀 | 😀 |
| មធ្យោបាយបញ្ឈប់កំណើត | មួយជីវិត | 😀 | ☹️ | 😀 |

**សម្គាល់៖** 🟢 បាទ/ចាស 🟡 ធម្មតា 🔴 ទេ

| ចំណាយថវិកាតិច | ងាយស្រួលប្រើ | មានរដូវតិច | មានផលរំខានតិចតួច | ងាយចាប់ផ្ដើមនិងឈប់ប្រើ | ការពារការឆ្លងមេរោគអេដស៍និងជំងឺកាមរោគ |
|---|---|---|---|---|---|
| បាទ/ចាស | បាទ/ចាស | ទេ | បាទ/ចាស | ធម្មតា | ទេ |
| បាទ/ចាស | បាទ/ចាស | ធម្មតា | ធម្មតា | ធម្មតា | ទេ |
| ធម្មតា | ធម្មតា | ធម្មតា | ទេ | ធម្មតា | ទេ |
| ធម្មតា | ទេ | បាទ/ចាស | ធម្មតា | បាទ/ចាស | ទេ |
| ធម្មតា | ទេ | ទេ | បាទ/ចាស | បាទ/ចាស | បាទ/ចាស |
| ទេ | ធម្មតា | ទេ | ធម្មតា | បាទ/ចាស | ទេ |
| បាទ/ចាស | បាទ/ចាស | ទេ | បាទ/ចាស | ទេ | ទេ |

# ចំណុចគួរពិចារណា

| | | |
|---|---|---|
|  កងដាក់ក្នុងស្បូន | • សមស្របចំពោះស្ត្រីដែលមិនអាចប្រើមធ្យោបាយពន្យារកំណើតមានជាតិអ័រម៉ូន<br>• អាចការពារជំងឺមហារីកស្រទាប់ក្នុងនៃស្បូន | • អាចឈឺចាប់តិចតួចក្នុងពេល ឬបន្ទាប់ពីការដាក់កងភ្លាម<br>• អាចមានការប្រែប្រួលការធ្លាក់ឈាមរដូវ |
|  កងដាក់ក្រោមស្បែក | • មិនចាំបាច់ត្រូវចងចាំលេបថ្នាំរាល់ថ្ងៃ ឬចាក់ថ្នាំរាល់ ៣ខែម្តង<br>• អាចការពារភាពស្លេកស្លាំង | • អាចមានឈាមរដូវមិនទៀងទាត់<br>• អាចបាត់ឈាមរដូវមួយរយៈ |
|  ថ្នាំចាក់ពន្យារកំណើត | • មិនប៉ះពាល់ដល់បរិមាណ និងគុណភាពទឹកដោះម្តាយ<br>• អាចបន្ថយភាពស្លេកស្លាំង | • អាចដោះឡើងតឹង<br>• អាចប្រែប្រួលទម្ងន់<br>• អាចមានឈាមរដូវមិនទៀងទាត់ |
|  ថ្នាំគ្រាប់ពន្យារកំណើត | • បន្ថយការឈឺចាប់នៅពេលមានឈាមរដូវ និងពេលមេជីវិតញីធ្លាក់<br>• អាចជួយកាត់បន្ថយការកើតមុន | • មានអារម្មណ៍ហាក់ដូចជាចាញ់កូន |
|  ស្រោមអនាម័យ | • ការពារការមានផ្ទៃពោះ និងជំងឺកាមរោគផ្សេងៗ<br>• មិនចាំបាច់វេជ្ជបណ្ឌិតពិនិត្យសុខភាព | • មិនមានផលរំខាន |

# ចំណុចគួរពិចារណា

| | | |
|---|---|---|
|  ៧២ ម៉ោង<br>ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ | • មានប្រសិទ្ធភាពខ្ពស់ ការពារការ មានផ្ទៃពោះ ប្រសិនបើឆាប់ប្រើក្រោយការរួមភេទក្នុងអំឡុងពេល ៧២ម៉ោង ដោយមិនបានប្រើមធ្យោបាយពន្យារកំណើតណាមួយ | • អាចមានអាការៈ ដូចជាឈឺក្បាល ដោះឡើងតឹង វិលមុខ អស់កំលាំងល្ហិតល្ហៃ ចង្អោរក្អួត ធ្លាក់ឈាមតិចតួច ឈាមរដូវមិនទៀង |
|  ការវះកាត់ចងដៃស្បូន<br> ការចងបំពង់មេជីវិតបុរស | • សមស្របចំពោះបុរស/ស្ត្រី ដែលមិនចង់បានកូនទៀត ឬមានបញ្ហាផ្នែកវេជ្ជសាស្ត្រ<br>• បុរសទទួលខុសត្រូវចងបំពង់មេជីវិតឈ្មោល ដកបន្ទុកពីស្ត្រី ( ចងខាងបុរសក៏បាន ស្ត្រីក៏បាន )<br>• បង្កើនភាពរីករាយ និងចំនួនដងនៃការរួមភេទ<br>• គ្មានផលរំខាន់បន្ទាប់បន្សំ | • មិនអាចស្រាយនិងតភ្ជាប់ដូចដើមបានទេទាំងការចងដៃស្បូន និងការចងបំពង់បង្ហូរមេជីវិតឈ្មោល<br>• មិនអាចការពារឆ្លងរោគតាមផ្លូវបន្តពូជ<br>• គូស្វាមីត្រូវប្រើស្រោម ឬមធ្យោបាយពន្យារកំណើតដទៃទៀតយ៉ាងតិច ៣ខែសិន |

# សំណួរចម្លើយ៖ ពាក្យចរចាមអារាមពី មធ្យោបាយពន្យារកំណើតបែបទំនើប



កងដាក់ក្នុងស្បូន

**សំណួរ៖** តើវានឹងរបូតចេញទេ?

**ចម្លើយ៖** ទេ វាស្ថិតនៅក្នុងតួស្បូន ហើយវាចេញមកក្រៅបាន លុះត្រាតែពេលពេទ្យយកវាចេញវិញ។



កងដាក់ក្រោមស្បែក

**សំណួរ៖** តើគេដាក់កងក្រោមស្បែកនៅកន្លែងណា? តើវាប៉ះពាល់ដល់សរីរាង្គយើងទេ ដូចជាខ្សោយកំលាំង?

**ចម្លើយ៖** គេដាក់បញ្ចូលនៅផ្នែកដើមដៃ ហើយវាមិនប៉ះពាល់សរីរាង្គកាយអ្វីឡើយ។



ថ្នាំចាក់ពន្យារកំណើត

**សំណួរ៖** តើខ្ញុំត្រូវចាក់ថ្នាំពន្យារកំណើតរហូតមែនទេ? តើខ្ញុំអាចត្រលប់មកមានកូនវិញដែរឬទេ?

**ចម្លើយ៖** ទេ លោកអ្នកអាចឈប់ចាក់ ពេលអ្នកចង់ត្រលប់មកដូចដើមវិញ ឬពេលចង់មានកូន។



ថ្នាំគ្រាប់ពន្យារកំណើត

**សំណួរ៖** តើខ្ញុំត្រូវលេបរាល់ថ្ងៃមែនទេ? តើវាអាចប៉ះពាល់ដល់ក្រពះឬទេ?

**ចម្លើយ៖** ពិតណាស់ អ្នកត្រូវលេបថ្នាំរាល់ថ្ងៃ ប្រសិនបើអ្នកឈប់លេប អ្នកនឹងមានកូន។ ការលេបថ្នាំនេះមិនបង្កផលប៉ះពាល់ដល់ក្រពះទេ។



ស្រោមអនាម័យ

**សំណួរ៖** តើការប្រើស្រោមអាចបង្កឱ្យមានបញ្ហារលាកមាត់ស្បូនដែរទេ? តើការប៉ះពាល់ទឹករំអិលលើស្រោមអនាម័យបង្កផលប៉ះពាល់ដល់សុខភាពដែរទេ?

**ចម្លើយ៖** ការប្រើស្រោមអនាម័យមិនបង្កឱ្យមានជំងឺរលាកមាត់ស្បូនទេ ហើយការប៉ះពាល់ទឹករំអិលលើស្រោមអនាម័យក៏មិនបង្កប៉ះពាល់ដល់សុខភាពដែរ។

# សំណួរចម្លើយ៖ ពាក្យចចាមអារាមពី
# មធ្យោបាយពន្យារកំណើតបែបទំនើប




ថ្នាំគ្រាប់ការពារកំណើតបន្ទាន់

**សំណួរ៖** ស្រ្តីអាចប្រើថ្នាំគ្រាប់ការពារកំណើតបន្ទាន់ជាមធ្យោបាយការពារកំណើតទៀងទាត់បានទេ ?

**ចម្លើយ៖** ទេ មធ្យោបាយការពារកំណើតផ្សេងៗទៀតស្ទើរតែទាំងអស់មានប្រសិទ្ធភាពជាងថ្នាំគ្រាប់ការពារកំណើតបន្ទាន់ក្នុងការការពារការមានផ្ទៃពោះ។



ការវះកាត់ចងដៃស្បូន

**សំណួរ៖** តើការចងដៃស្បូនអាចស្រាយវិញបានទេ ?
តើស្រ្តីនឹងបាត់ចំណង់ផ្លូវភេទទេ ?

**ចម្លើយ៖** ទេ គាត់នឹងរីករាយក្នុងការរួមភេទជាងមុន ដោយសារគាត់អស់បារម្ភពីការមានផ្ទៃពោះ។



ការចងបំពង់មេជីវិតបុរស

**សំណួរ៖** តើការវះចងបំពង់មេជីវិតបុរសនាំអោយបុរសបាត់បង់សមត្ថភាពផ្លូវភេទទេ ?តើធ្វើឱ្យខ្សោយដែរទេ ?

**ចម្លើយ៖** ទេ គាត់អាចរួមភេទបានដូចពីមុន លិង្គគាត់នឹងឡើងរឹងដូចពីមុន ហើយបញ្ចេញទឹកកាមដូចមុន គាត់អាចធ្វើការដូចធម្មតា។

# ផែនការបង្កើនចំណងស្នេហ៍ទៅថ្ងៃអនាគត៖



យើងមានផែនការយកកូន



សន្សំលុយដើម្បីសម្រេច
គោលដៅរបស់យើង



យើងស្រលាញ់គ្នារហូត
ចាស់កោងខ្នង



យើងចង់មានរថយន្តមួយគ្រឿង



យើងចង់សង់ផ្ទះ



យើងមានផែនការដើរកំសាន្ត
ទូទាំងប្រទេស

# ចំណងស្នេហ៍



# សូមទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ក្បែរផ្ទះ ដើម្បីសួរព័ត៌មាន និងជ្រើសរើសយក មធ្យោបាយពន្យារកំណើតបែបទំនើប សមស្របសម្រាប់អ្នក

ភ្នាក់ងារអប់រំ៖ ..................................................

លេខទំនាក់ទំនង៖ ..................................................

ភ្នាក់ងារអប់រំ៖ ..................................................

លេខទំនាក់ទំនង៖ ..................................................

**ព័ត៌មានបន្ថែមសូមហៅទៅលេខ**

| | |
|---|---|
| cellcard | 012 999 124 \| 078 999 124 |
| Smart | 010 485 585 |

USAID
ជំនួយពីពលរដ្ឋអាមេរិក

psi Cambodia